# ចំណាប់អារម្មណ៍គន្លឹះរបស់ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស TWG ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី២ ឆ្នាំ២០២៥ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី ១៥ កញ្ញា ២០២៥

ជាបឋម ខ្ញុំបាទ សឿង សារឿន នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា ដែលជាលេខាធិការ និងតំណាងក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ សូមគោរព៖

- ឯកឧត្ដម រស់ សីលវ៉ា អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- លោក Bryan Fornari, ប្រធានកិច្ចសហប្រតិបត្តិការ សហភាពអឺរ៉ុបប្រចាំនៅកម្ពុជា លោក Anthony Gill តំណាងធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំប្រទេសកម្ពុជា សហប្រធានអង្គប្រជុំ។
- ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញាទាំងអស់ ជាថ្នាក់ដឹកនាំ និងជាសមាជិកគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តំណាងស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល។

ខ្ញុំ តំណាងឲ្យក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ សូមអបអរសាទរចំពោះភាពរីកចម្រើនដ៏គួរឲ្យកត់សម្គាល់នៃដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ឆ្នាំ ២០២៣-២០២៧ "គណនេយ្យភាពសមិទ្ធកម្ម" ជាពិសេសវឌ្ឍនភាពប្រចាំត្រីមាសទី២ ឆ្នាំ២០២៥ សំខាន់ៗទាំង៦ចំណុចធំៗ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង/ស្ថាប័ន និងមន្ទីរនានា។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ជាពិសេសស ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ថ្នាក់ដឹកនាំក្រសួងទាំងអស់ សម្រាប់កិច្ចសហប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។

សូមកោតសរសើរចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការដាក់បញ្ចូលសូចនាករនៃសន្ទស្សន៍ការអង្កេតថវិកាបើកចំហ Open Budget Survey (OBS) ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ២០២៤ - ២០២៨ ដែលទើបអនុម័ត និងដាក់ឲ្យអនុវត្តកាលពីខែឧសភា-មិថុនាកន្លងទៅថ្មីៗនេះ។

ទន្ទឹមនឹងការរីកចម្រើនដូចបានរៀបរាប់ខាងលើនេះ យើងខ្ញុំសូមចូលរួមជាមតិយោបល់សំរាប់រាជរដ្ឋាភិបាលពិចារណា ដែលបានសំរង់ចេញពីការវិភាគច្បាប់ថវិកាជាតិឆ្នាំ២០២៥ សំរាប់ឆ្នាំ២០២៦ ដែលបានដាក់ជូនរាជរដ្ឋាភិបាលកាលពីខែសីហា កន្លងមកនេះ ដូចខាងក្រោម៖

អង្គការសង្គមស៊ីវិល សាទរ និងស្វាគមន៍ចំពោះការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលក្នុងការកែសម្រួលវិធីសាស្រ្តគណនាពន្ធអាករ និងកំណត់ពេលវេលាសម្រាប់ការដំឡើងអត្រាពន្ធអាករសម្រាប់គ្រឿងស្រវឹង ថ្នាំជក់ និងភេសជ្ជៈផ្អែម តាមរបៀបដែលអាចព្យាករណ៍បាន។ អង្គការសង្គមស៊ីវិល មានការព្រួយបារម្ភអំពីផលប៉ះពាល់អវិជ្ជមាននៃផលិតផលទាំងនេះ ជាពិសេសគ្រឿងស្រវឹង និងភេសជ្ជៈផ្អែម លើសុខភាពរបស់អ្នកប្រើប្រាស់ ដែលបង្ហាញឱ្យឃើញពីការកើនឡើងនៃជំងឺមិនឆ្លង ដូចជាជំងឺទឹកនោមផ្អែម និងជំងឺលើសឈាមដែលត្រូវបានរាយការណ៍ដោយក្រសួងសុខាភិបាលនៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០២៤។ **អង្គការសង្គមស៊ីវិលទន្ទឹងរង់ចាំមើលការកើនឡើងនៃអត្រាពន្ធលើផលិតផលទាំងនេះ និងការអនុវត្តនៅឆ្នាំ ២០២៦។ យើងក៏ស្នើសុំឱ្យ រាជរដ្ឋាភិបាល ពង្រឹងស្តង់ដារ និងអភិបាលកិច្ចនៃផលិតផលដែលមានមាតិកាជាតិស្ករខ្ពស់ រួមទាំងភេសជ្ជៈផ្អែម និងធ្វើការសិក្សាលទ្ធភាពលើសក្តានុពលនៃការកើនឡើងពន្ធអាករផងដែរ។**

## ផ្នែកចំណូល

បង្កើនប្រាក់ចំណូលពន្ធលើអចលនទ្រព្យ៖ **កែលម្អការចុះបញ្ជីអចលនទ្រព្យ ពង្រីកមូលដ្ឋានពន្ធ ធ្វើបច្ចុប្បន្នភាពការវាយតម្លៃតម្លៃទីផ្សារ និងពង្រឹងការគ្រប់គ្រងតាមវិធានការបច្ចេកវិទ្យា។** ផ្តល់ការបន្ធូរបន្ថយពន្ធ ដើម្បីដោះស្រាយបញ្ហាសមធម៌សង្គម **និងអនុវត្តអត្រាពន្ធកើន**ជាពិសេសលើដីដែលមិនបានប្រើប្រាស់ ដើម្បីបង្កើនសមធម៌ និងចំណូលជាតិ។

## ការចំណាយសម្រាប់វិស័យអប់រំ សុខាភិបាល និងកិច្ចគាំពារសង្គមនៅក្រោមខ្ទង់ថវិកានៃក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ៖

1. រាជរដ្ឋាភិបាលគប្បីចាត់អាទិភាពលើការផ្តល់មូលនិធិដ៏ខ្លាំងក្លាដល់វិស័យសំខាន់ៗ នោះគឺ វិស័យអប់រំ សុខាភិបាល និងសង្គមកិច្ច។ ការចាត់អាទិភាពនេះពាក់ព័ន្ធនឹងការបង្កើនការវិភាជថវិកាទៅដល់វិស័យទាំងនេះស្របពេលតំណាលគ្នានេះ ផ្តោតការយកចិត្តទុកដាក់លើការពង្រឹងគុណភាពនៃការផ្តល់សេវា។ ម៉្យាងវិញទៀត ដើម្បីកាត់បន្ថយការចំណាយសុខភាពប្រជាជនលើជម្ងឺទូទៅឬជម្ងឺមិនឆ្លង រដ្ឋាភិបាលគួរពិចារណាក្នុងការចំណាយថ្លៃពិនិត្យ សុខភាពដល់ប្រជាជនទូទៅចាប់ពីអាយុ ៣៥ ដល់ ៥០ឲ្យបាន២ដងក្នុងមួយឆ្នាំ ដើម្បីធានាថា ការថែទាំសុខភាពមុនឈានទៅដល់ការចំណាយច្រើន។ ស្នើវិភាជថវិកា ៥,១% នៃ GDP ដល់កិច្ចគាំពារសង្គម តាមអនុសាសន៍សកលសម្រាប់ប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។

2. រាជរដ្ឋាភិបាលបន្តពង្រីកទំហំថវិកាទៅរដ្ឋបាលថ្នាក់ក្រោមជាតិរហូតដល់៣០% (១០% ថ្នាក់ខេត្ត ១០% ថ្នាក់ស្រុក/ខណ្ឌ និង ១០% ថ្នាក់ឃុំ/សង្កាត់) នៃថវិការដ្ឋ។ ដើម្បីជួយសម្រាលដល់ទុកលំបាករបស់ក្រុមជនងាយរងគ្រោះស្ត្រីកុមារនៅមូលដ្ឋាន រដ្ឋាភិបាល គួរវិភាជថវិកាចំណាយប្រចាំឆ្នាំលើការងារសង្គម សេវាសាធារៈដល់ថ្នាក់ក្រោមជាតិ ឃុំសង្កាត់ (ពិសេសសេវាសុខភាព ការអប់រំ និងបរិស្ថាន អេកូឡូស៊ី) ជាពិសេសឃុំ/សង្កាត់ដែលស្ថិតនៅតំបន់ជនបទដាច់ស្រយាលតាមបណ្តោយព្រំដែន ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុនពីមួយឆ្នាំទៅឆ្នាំ ដើម្បីកាត់បន្ថយហានិភ័យផ្សេងៗដល់ជីវភាពរស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

**ការចំណាយមិនបានគ្រោងទុក (ថវិកាបម្រុង)៖**

3. ប្រទេសកម្ពុជាប្រឈមមុខនឹងឱនភាពថវិកាប្រចាំឆ្នាំជាបន្តបន្ទាប់ ដែលធ្វើឱ្យរាជរដ្ឋាភិបាលចាំបាច់ត្រូវកាត់បន្ថយការចំណាយមិនបានគ្រោងទុកនេះឱ្យនៅត្រឹមមិនលើសពី ៣% ជារៀងរាល់ឆ្នាំ។ ការកាត់បន្ថយនេះ គឺជាការចាំបាច់ដើម្បីវិភាជធនធានកាន់តែច្រើនទៅដល់វិស័យសំខាន់ៗ ដូចជាវិស័យសុខាភិបាល អប់រំ និងកិច្ចគាំពារសង្គម។
4. លើកកម្ពស់តម្លាភាព និងគណនេយ្យភាពតាមរយៈការលើកកម្ពស់ការបើកឲ្យសាធារណៈជនអាចចូលប្រើប្រាស់ និងផ្តល់ការធ្វើបច្ចុប្បន្នភាពតាមកាលកំណត់លើព័ត៌មានថវិកាសំខាន់ៗដោយក្រសួងស្ថាប័នពាក់ព័ន្ធ និងវិស័យធំៗ ដូចជាការប្រមូលចំណូល ផែនការចំណាយ និងការប្រតិបត្តិ និងសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរដ្ឋ។
5. ស្នើសុំការចែករម្លែក និងចូលរួមពិគ្រោះយោបល់លើឯកសារព្រាងគោលនយោបាយ និងសេចក្តីណែនាំពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ និងដំណើរការលទ្ធកម្មសាធារណៈតាមក្រសួងស្ថាប័នរដ្ឋនានា។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញាទាំងអស់ ជាថ្នាក់ដឹកនាំ និងជាសមាជិកគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តំណាងស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល!**

6. អង្គការសង្គមស៊ីវិលក៏បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់យើងសម្រាប់ការរួមចំណែករបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាទាំងកំរិតជាតិ និងថ្នាក់ក្រោមជាតិ។ យើងខ្ញុំសូមជម្រាបជូនថា ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលមានសមាសភាពសមាជិកចំនួន២៩អង្គការជាតិ និងអន្តរជាតិ និងបានបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំថ្មី ដែលមានអង្គការសីលការ ជាប្រធាន អង្គការអុកស្វាមកម្ពុជា ជាអនុប្រធាន និងអង្គការ NGO Forum ជាលេខាធិការសម្រាប់អាណត្តិថ្មី ២០២៥ - ២០២៨ នេះ។ ដើម្បីពង្រឹងតម្លាភាពសារពើពន្ធ និងគណនេយ្យភាព ដោយមានការចូលរួមពីប្រជាពលរដ្ឋ តាមរយៈការផ្តល់មូលនិធិដល់អង្គការសង្គមស៊ីវិល ដែលមានអង្គការ Oxfam អង្គការNGO Forum, SILAKA និង API រួមគ្នាដឹកនាំអនុវត្តគម្រោងនេះ ជាមួយនឹងសមាជិកក្រុមការងារថវិកា ដែលចាប់ផ្តើមអនុវត្តពីខែមិថុនា ឆ្នាំ ២០២៥ ដល់ខែ ឧសភា ឆ្នាំ២០២៨ ក្នុងគោលបំណងចូលរួមចំណែកដើម្បីពង្រឹងការចូលរួមរបស់ពលរដ្ឋ ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាព ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយបរិយាបន្ន។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សភាពអឺរ៉ុប ដែលបន្តប្តេជ្ញាចិត្តខ្ពស់រួមគ្នារវាងសហភាពអឺរ៉ុប និងរាជរដ្ឋាភិបាលកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមស្នើរនូវការបន្តកិច្ចសហប្រតិការដ៏ល្អពីក្រសួងស្ថាប័នរាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងអាជ្ញាធរសវនកម្មជាតិ ស្នើសុំឲ្យមានអនុសារណយោគយល់គ្នា ឫក្របខណ្ឌការងាររួមគ្នា និងយើងខ្ញុំក៏ស្នើរសុំនូវការធ្វើបច្ចុប្បន្នភាពក្របខណ្ឌការងាររវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមការងារថវិកា នៃអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ ពីកម្រិតអ្នកសង្កេតការណ៍ ទៅជាសមាជិកពេញលេញ ក្នុងក្រុមការងារ

បច្ចេកទេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMR TWG) ផងដែរដើម្បីចូលរួមក្នុងការសម្រេចបានគោលដៅរួមគ្នា។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ នឹងទទួលយកនូវមតិយោបល់សំណើកែលម្អចូលទៅក្នុងផែនការ និងការអនុវត្តជាក់ស្តែង និងធានាការចូលរួមប្រកបដោយអត្ថន័យសម្រាប់ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល នៅក្នុងដំណើរការអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៤ ឆ្នាំ ២០២៣-២០២៧ ជាបន្តទៅទៀត ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជា ឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ខ្ញុំបាទ សូមគោរពជូនពរដល់ឯកឧត្តមគណៈអធិបតី និងអ្នកចូលរួមទាំងអស់បានជួបតែសេចក្តីសុខ សុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច ជានិរន្ត និងសូមអនុមោទនាពិធីបុណ្យកាន់បិណ្ឌ។

សូមគោរពអរគុណ!